- ចូលរួមស្តាប់ និងតាមដានដោយប្រុងប្រយត្ន័បំផុតក្នុងអំឡុងពេលឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ចាប់ពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ។

- ពិនិត្យមើលបេក្ខជននៃបញ្ជីគណបក្ស ថាតើមានដាក់បេក្ខជន ប្រុស-ស្ត្រីឆ្លាស់គ្នា នៅលេខរៀងខាងលើឬទេ? ព្រោះអ្នក ដែលនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ច្រើន។
- ហ៊ានសួរដេញដោលទៅបេក្ខជន និងគណបក្សនយោបាយនីមួយៗអំពីយុទ្ធសាស្ត្រ ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់យើង ។
- ចេះស្រាវជ្រាវ និងពិភាក្សាជាមួយអ្នកជិតខាង និងបងប្អូនក្នុងមូលដ្ឋាន រកព័ត៌មានបន្ថែមពីបេក្ខជន គណបក្សនយោបាយ ។

**កុំភ្លេចទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨**

- បានជ្រើសរើសគណបក្ស និងបេក្ខជនតំណាងរាស្ត្រទៅតាមឆន្ទៈ
- ទម្លាក់គណបក្ស និងតំណាងរាស្ត្រដែលយើង មិនពេញចិត្ត
- បានបំពេញកាតព្វកិច្ច និងអនុវត្តសិទ្ធិចូលរួមបោះឆ្នោតរបស់ខ្លួន

លោក អ្នកគួរអនុវត្តតាម ៣ ចំណុច "ត្រូវ" និង ២ ចំណុច "មិនត្រូវ"

## ៣ចំណុច "ត្រូវ"

១. ត្រូវ ស្វះស្វែង ព្យាយាម តាមដានដោយយកចិត្តទុកដាក់រាល់ការអប់រំផ្សព្វផ្សាយ ទាក់ទងនឹងការបោះឆ្នោតពីអាជ្ញាធររៀបចំការបោះឆ្នោត អង្គការ-សមាគមមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងការឃោសនារបស់គណបក្សនយោបាយ។
២. ត្រូវ អប់រំ ផ្សព្វផ្សាយបន្ត ដល់បងប្អូន អ្នកជិតខាង និងមិត្តភ័ក្តិរបស់ខ្លួន
៣. ត្រូវ ដោះស្រាយដោយសន្តិវិធី និងសុវត្ថិភាពផ្ទាល់ខ្លួននៅពេលជួបការគំរាមកំហែងបង្ខំអោយធ្វើសម្បថ ឬបង្ខិតបង្ខំផ្សេងៗ ។

## ២ចំណុច "មិនត្រូវ"

១. មិនត្រូវបាក់ទឹកចិត្តទៅបោះឆ្នោត
២. មិនត្រូវ សំរេចបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយដោយការទិញទឹកចិត្តបន្តិចបន្តួច ឬ ការគំរាមកំហែង ។

# ផលវិបាកនៃការលក់ទិញសន្លឹកឆ្នោត

អំណាចដែលបានមកពីការទិញ លក់សន្លឹកឆ្នោត វាធ្វើអោយ ÷

**អ្នកបោះឆ្នោតទទួលបាន**

- លោក អ្នកក្លាយជាទាសករនៃអំណាច
- តំណាងជាប់ឆ្នោតពុំដោះស្រាយបញ្ហានិង
- ឈានទៅរកការរំលោភច្បាប់ និងប្រព្រឹត្តិអំពើពុករលួយ

**សង្គមទទួលបាន**

- មានការរំលោភអំណាច, រំលោភច្បាប់ មិនគោរពសិទ្ធិមនុស្ស គ្មានប្រជាធិបតេយ្យ គ្មានយុត្តិធម៌
- មានអំពើពុករលួយ
- គ្មានការអភិវឌ្ឍន៍ និងបន្តភាពក្រីក្រ ។